ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានរតនាគារជាតិ

អគារលេខ១៩ រុក្ខវិថីព្រះមហាក្សត្រីយានីកុសមៈ
(ផ្លូវលេខ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ ០៩៧ ៣៣៣ ៨៥០៥

ទូរសារ៖ ០២៣ ៧២២ ៨១៥

អ៊ីម៉ែល៖ info@treasury.gov.kh

វេបសាយ៖ www.treasury.gov.kh


ទាញយកឯកសារ

# ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

(ក្នុងទម្រង់ថវិកាពលរដ្ឋ-Citizen Budget Format)




ឆ្នាំ២០២៤

# មាតិកា


១ សេចក្តីផ្តើម

២ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

៣ ចំណូលនិងចំណាយថវិការដ្ឋ

៤ តុល្យភាពនៃថវិកាថ្នាក់ជាតិ

៥ ចំណូលនិងចំណាយថវិកាថ្នាក់ជាតិ

៦ ចំណូលនិងចំណាយថវិកាថ្នាក់ក្រោមជាតិ

៧ លទ្ធផលទទួលបានពីការអនុវត្តថវិកាសម្រាប់គាំទ្រអាទិភាពគោលនយោបាយ

៨ សេចក្តីសន្និដ្ឋាន

# ១.សេចក្ដីផ្ដើម

- ជាលទ្ធផលនៃការអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ក្រោមការដឹកនាំចង្អុលបង្ហាញ និងគាំទ្រជាប្រចាំដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៦ នៃរដ្ឋសភាក្នុងឋានៈជាអគ្គមេបញ្ជាការតែមួយនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។




- រៀបចំឡើងដោយគោរពបានទាំងស្រុងទាំងកាលវសាន ទាំងខ្លឹមសារ តាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

## ដំណើរការនៃការរៀបចំ

១- បូកសរុបទិន្នន័យចំណូល ចំណាយ ដែលកត់ត្រាដោយគណនេយ្យករសាធារណៈ។
២- ផ្ទៀងផ្ទាត់ត្រឹមត្រូវជាមួយអាណាប័កពាក់ព័ន្ធ ទាំងថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ។
៣- ប្រជុំពិនិត្យល្អិតល្អន់ ក្នុងកម្រិតផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
៤- បញ្ចប់សេចក្ដីព្រាងច្បាប់ និងបញ្ជូនទៅគណៈរដ្ឋមន្ត្រីនៅអំឡុងដើមខែតុលា ឆ្នាំ២០២៤។

## ដំណើរការនៃការអនុម័ត

១- ត្រូវបានដាក់ឆ្លងគណៈរដ្ឋមន្ត្រី ពិនិត្យ និងសម្រេចក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤។
២- ត្រូវបានពិនិត្យ និងអនុម័តយល់ព្រមនៅសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៧ នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤។
៣- ត្រូវបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងនៅសម័យប្រជុំព្រឹទ្ធសភាលើកទី២ នីតិកាលទី៥ នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤។
៤- ត្រូវបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២២៤/០០៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ ២០២៤។

# ២.ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

### ១ កំណើនសេដ្ឋកិច្ចតាមថ្លៃថេរ

- **ឆ្នាំ២០២៣៖ ៥,០%**
- ឆ្នាំ២០២២៖ ៥,២%
- ឆ្នាំ២០២១៖ ៣,០%

### ២ ផ.ស.ស. សម្រាប់មនុស្ស ម្នាក់

- **ឆ្នាំ២០២៣៖ ២ ៥២០ដុល្លារអាម៉េរិក**
- ឆ្នាំ២០២២៖ ២ ៣៨៣ដុល្លារអាម៉េរិក
- ឆ្នាំ២០២១៖ ១ ៦៥៩ដុល្លារអាម៉េរិក

### ៣ អតិផរណាមធ្យមប្រចាំឆ្នាំ

- **ឆ្នាំ២០២៣៖ ២,១%**
- ឆ្នាំ២០២២៖ ៥,៣%
- ឆ្នាំ២០២១៖ ២,៩%




### ៤ អត្រាប្តូរប្រាក់ក្នុងមួយដុល្លារអាម៉េរិក

- **ឆ្នាំ២០២៣៖ ៤ ១១០ រៀល**
- ឆ្នាំ២០២២៖ ៤ ០៩០ រៀល
- ឆ្នាំ២០២១៖ ៤ ០៦៨ រៀល

### ៥ សមតុល្យគណនីចរន្ត នៃផ.ស.ស.

- **ឆ្នាំ២០២៣៖ +១,៣%**
- ឆ្នាំ២០២២៖ -២៥,៦%
- ឆ្នាំ២០២១៖ -៤៥,៤%

### ៦ ទុនបម្រុងអន្តរជាតិ

| លានដុល្លារអាម៉េរិក | ចំនួនខែនៃការនាំចូល |
|---|---|
| **ឆ្នាំ២០២៣៖ ១៩ ៩៩៨** | **ឆ្នាំ២០២៣៖ ៨,២** |
| ឆ្នាំ២០២២៖ ១៧ ៨០៥ | ឆ្នាំ២០២២៖ ៦,១ |
| ឆ្នាំ២០២១៖ ២០ ២៦៥ | ឆ្នាំ២០២១៖ ៧,៤ |

# ៣-ចំណូលនិងចំណាយថវិការដ្ឋ



# ៣-ចំណូលនិងចំណាយថវិការដ្ឋ

នៅក្នុងឆ្នាំ២០២៣ ចំណូលថវិការដ្ឋ(ថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ) អនុវត្តបានចំនួន៣៨ ៧០១ ៩៧៦,៥លានរៀល ត្រូវជា២១,៨៦%នៃផ.ស.ស. និងចំណាយថវិការដ្ឋ(ថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិដែលបានដកឧបត្ថម្ភធនពីថវិកាថ្នាក់ជាតិ) អនុវត្តបានចំនួន៣៨ ៣៥៥ ៥០៣,១លានរៀល ត្រូវជា ២១,៦៧%នៃផ.ស.ស. ។

ឯកតា៖ លានរៀល

| កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ | ចំណូលថវិកា | ចំណាយថវិកា | អតិរេក/ឱនភាពពីការអនុវត្តថវិកាក្នុងឆ្នាំ |
|---|---|---|---|
| ឆ្លងកាត់រតនាគារជាតិ | ២៦ ៧៨៦ ៨៩៣,៧ | ២៩ ០១០ ៧៧៤,៦ | -២ ២២៣ ៨៨០,៨ |
| មិនឆ្លងកាត់រតនាគារជាតិ | ៥ ៨៦៦ ០៦២,០ | ៥ ៨៦៦ ០៦២,០ | ០ |
| សរុប | ៣២ ៦៥២ ៩៥៥,៧ | ៣៤ ៨៧៦ ៨៣៦,៥ | -២ ២២៣ ៨៨០,៨ |

| កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ក្រោមជាតិ | ចំណូលថវិកា | ចំណាយថវិកា | អតិរេក/ឱនភាពពីការអនុវត្តថវិកាក្នុងឆ្នាំ |
|---|---|---|---|
| រដ្ឋបាលរាជធានី ខេត្ត | ៤ ១៨១ ៩២៦,១ | ៤ ១៧៣ ៣៥៩,២ | +៨ ៥៦៦,៩ |
| រដ្ឋបាលក្រុង ស្រុក | ៦៥៩ ២៩៤,៨ | ៦៥០ ១១១,០ | +៩ ១៨៣,៨ |
| រដ្ឋបាលឃុំ សង្កាត់ | ១ ២៨៧ ២៣៤,៨ | ១ ១០៧ ៨២៦,៥ | +១៧៩ ៤០៨,៣ |
| សរុប | ៦ ០៤៩ ០២០,៧ * | ៥ ៨៥១ ៨៦១,៧* | +១៩៧ ១៥៩,០ |

* តួលេខនេះ ត្រូវបានដកតួលេខចំណូលសារពើពន្ធចែករំលែកនៅរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៧៩ ៤៣៥លានរៀល ដែលបានកត់ត្រាជាចំណាយថវិការដ្ឋបាលរាជធានី ខេត្ត និងជាចំណូលថវិការដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់។

# ៤-តុល្យភាពនៃថវិកាថ្នាក់ជាតិ



# ៤-តុល្យភាពនៃថវិកាថ្នាក់ជាតិ

ឯកតា៖ លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ | ចំនួនទឹកប្រាក់ | តុល្យភាព/ហិរញ្ញប្បទាន |
|---|---|---|
| ចំណូលចរន្ត | ២៤ ៦៤១ ៤១៥,០ | |
| ចំណាយចរន្ត | ២១ ៣៦៧ ២២៦,៣ | |
| អតិរេកនៃថវិកាចរន្ត | **(+)៣ ២៧៤ ១៨៨,៨** | |
| ចំណូលមូលធន | ៤២ ៤១៤,៥ | |
| ចំណាយមូលធន | ១១ ៨៥២ ០៥៥,១ | |
| ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ | **(-)៨ ៥៣៥ ៤៥១,៨** | |
| ហិរញ្ញប្បទាននៃឱនភាព | | **(+)៨ ៥៣៥ ៤៥១,៨** |
| ហិរញ្ញប្បទានក្រៅប្រទេស | | (+)៦ ០៧៣ ៥៧១,០ |
| ហិរញ្ញប្បទានក្នុងប្រទេស | | (+)២ ៤៦១ ៨៨០,៨ |
| បោះផ្សាយមូលបត្ររដ្ឋ | | (+)២៣៨ ០០០,០ |
| បញ្ញើរាជរដ្ឋាភិបាល | | (+)២ ២២៣ ៨៨០,៨ |

# ៥-ចំណូលនិងចំណាយថវិកាថ្នាក់ជាតិ



៥.១- ចំណូលថ្នាក់ជាតិ

៥.១.១-ចំណូលចរន្តថ្នាក់ជាតិ

៥.១.២-ចំណូលមូលធនថ្នាក់ជាតិ

៥.២-ចំណាយថវិកាថ្នាក់ជាតិ

៥.២.១-ចំណាយចរន្តថ្នាក់ជាតិ

៥.២.២-ចំណាយមូលធនថ្នាក់ជាតិ

៥.៣-ហិរញ្ញប្បទាន

៥.៤-ស្ថានភាពបំណុល

# ៥.ចំណូលនិងចំណាយថវិកាថ្នាក់ជាតិ

## ៥.១- ចំណូលថវិកាថ្នាក់ជាតិ

ចំណូលថវិកាថ្នាក់ជាតិឆ្នាំ២០២៣ អនុវត្តបានចំនួន៣២ ៦៥២ ៩៥៥,៧លានរៀល ត្រូវជា ១៨,៤៤%នៃផ.ស.ស. ក្នុងនោះ៖

- ចំណូលចរន្តថវិកាថ្នាក់ជាតិ អនុវត្តបានចំនួន២៤ ៦៤១ ៤១៥,០លានរៀល ត្រូវជា ១៣,៩២%នៃផ.ស.ស. ដែលជាចំណូលអនុវត្តឆ្លងកាត់រតនាគារជាតិទាំងអស់។
- ចំណូលមូលធនថវិកាថ្នាក់ជាតិ អនុវត្តបានចំនួន៨ ០១១ ៥៤០,៧លានរៀល ក្នុងនោះ៖
    - ចំណូលមូលធនថវិកាថ្នាក់ជាតិអនុវត្តឆ្លងកាត់រតនាគារជាតិមានចំនួន ២ ១៤៥ ៤៧៨,៧លានរៀល។
    - ចំណូលមូលធនថវិកាថ្នាក់ជាតិអនុវត្តមិនឆ្លងកាត់រតនាគារជាតិមានចំនួន ៥ ៨៦៦ ០៦២,០លានរៀល។

ឯកតា៖ ទ្រីលានរៀល






## ៥.១.១- ចំណូលចរន្តថ្នាក់ជាតិ




បើពិនិត្យលើការប្រមូលពន្ធក្នុងនិងក្រៅប្រទេសវិញ៖









## ៥.១.២- ចំណូលមូលធនថ្នាក់ជាតិ






## ៥.២-ចំណាយថវិកាថ្នាក់ជាតិ

ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៣ អនុវត្តបានចំនួន៣៤ ៨៧៦ ៨៣៦,៥លានរៀល ត្រូវជា ១៩,៧០%នៃផ.ស.ស. ក្នុងនោះ៖

- ចំណាយចរន្តថវិកាថ្នាក់ជាតិ អនុវត្តបានចំនួន ២១ ៣៦៧ ២២៦,៣ លានរៀល ត្រូវជា១២,០៧%នៃផ.ស.ស. ដែលជាចំណាយអនុវត្តឆ្លងកាត់រតនាគារជាតិទាំងអស់។
- ចំណាយមូលធនថវិកាថ្នាក់ជាតិ អនុវត្តបានចំនួន១៣ ៥០៩ ៦១០,៣លានរៀល ត្រូវជា៧,៦៣%នៃផ.ស.ស. ក្នុងនោះ៖
    - ចំណាយមូលធនថវិកាថ្នាក់ជាតិអនុវត្តឆ្លងកាត់រតនាគារជាតិ មានចំនួន៧ ៦៤៣ ៥៤៨,៣លានរៀល។
    - ចំណាយមូលធនថវិកាថ្នាក់ជាតិអនុវត្តមិនឆ្លងកាត់រតនាគារជាតិ មានចំនួន៥ ៨៦៦ ០៦២,០លានរៀល។



## ៥.២.១- ចំណាយចរន្តថ្នាក់ជាតិ




វិស័យរដ្ឋបាលទូទៅ
៣ ៦៤៧ ៥៥៣,៩ លានរៀល

វិស័យការពារជាតិ សន្តិសុខ និង
សណ្តាប់ធ្នាប់សាធារណៈ
៥ ២០៨ ៧៨៩,៩ លានរៀល

វិស័យសង្គមកិច្ច
៧ ២២២ ៤៥០,៦ លានរៀល

វិស័យសេដ្ឋកិច្ច
១ ៦៨៦ ៥៦២,៣ លានរៀល

ចំណាយមិនទាន់បែងចែក
៣ ៦០១ ៨៦៩,៥ លានរៀល

# ចំណាយចរន្តតាមក្រសួង ស្ថាប័ន

ឯកតា៖លានរៀល

## វិស័យរដ្ឋបាលទូទៅ

- ព្រះបរមរាជវាំង ១០៩ ៩២៧,០
- រដ្ឋសភា ១៨១ ៤០២,៨
- ព្រឹទ្ធសភា ៨០ ៤៩២,២
- ក្រុមប្រឹក្សាធម្មនុញ្ញ ១៦ ២១៤,៤
- ទីស្តីការគណៈរដ្ឋមន្ត្រី ៨៣៣ ៦៥៤,០
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១៣ ៩៩២,៦
- ក្រសួងអធិការកិច្ច ៤១ ៥៩៦,៨
- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១៦៩ ៧៨៤,០
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ ៥៧៧ ៤៨០,២
- ក្រសួងផែនការ ១១១ ០១១,២
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១២០ ៥៦៨,១
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ២៦៤ ៦៩២,៤
- អាជ្ញាធរសវនកម្មជាតិ ១៣ ០៩១,២
- អង្គភាពប្រឆាំងអំពើពុករលួយ ៤៨ ២១៨,៧
- ក្រសួងមុខងារសាធារណៈ ៦៥ ៤២៨,៤

## វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

- ក្រសួងការពារជាតិ ២ ៨១៤ ២៦៧,៦
- ក្រសួងមហាផ្ទៃ ២ ២០៣ ៤២០,៨
- ក្រសួងយុត្តិធម៌ ១៩១ ១០១,៥

## វិស័យសង្គមកិច្ច

- ក្រសួងព័ត៌មាន ៨៣ ៥៦០,៤
- ក្រសួងសុខាភិបាល ១ ១០១ ២៦២,៤
- ក្រសួងអប់រំ យុវជន និងកីឡា ៣ ៧២៥ ០៧៥,៤
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ១៨៣ ៩១៦,០
- ក្រសួងបរិស្ថាន ៩០ ៥៤១,៨
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១ ៥៩៣ ០៥១,១
- ក្រសួងធម្មការ និងសាសនា ៦៨ ៤៩៩,០
- ក្រសួងកិច្ចការនារី ៤៥ ៤៤១,៦
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៣៧១ ១០៣,០

## វិស័យសេដ្ឋកិច្ច

- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ៦៦ ០៤១,៤
- ក្រសួងរ៉ែ និងថាមពល ៨២ ១៣៨,៥
- ក្រសួងពាណិជ្ជកម្ម ១២៤ ២៥៨,៥
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២៦១ ៨២៣,៩
- ក្រសួងអភិវឌ្ឍន៍ជនបទ ១៩២ ០០០,៤
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ២០៨ ០៩៨,៦
- ក្រសួងសាធារណការ និងដឹកជញ្ជូន ៤៣៦ ២៦២,៨
- ក្រសួងទេសចរណ៍ ៨១ ៤៩៣,២
- ក្រសួងធនធានទឹក និងឧតុនិយម ១៧២ ៩៥៩,៨
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ៦១ ៤៨៥,២

## ៥.២.២- ចំណាយមូលធនថ្នាក់ជាតិ

**ចំណាយមូលធនថ្នាក់ជាតិ**

**១៣ ៥០៩ ៦១០,៣លានរៀល**

**ចំណាយវិនិយោគបែងចែកតាមក្រសួង ស្ថាប័ន**
**១ ៤៨៤ ៦៧៥,៤លានរៀល**

- ក្រសួងសាធារណការ និងដឹកជញ្ជូន
  ៥០៩ ៩៣៦,២លានរៀល
- ក្រសួងអភិវឌ្ឍន៍ជនបទ
  ៤៨១ ០២៥,៩លានរៀល
- ក្រសួងធនធានទឹកនិងឧតុនិយម
  ២៩១ ១៦៤,០លានរៀល
- ក្រសួងអប់រំ យុវជន និងកីឡា
  ៧០ ៣០៤,៩លានរៀល
- ក្រសួងសុខាភិបាល
  ៥០ ៣៥៨,៨លានរៀល
- ក្រសួងមហាផ្ទៃ
  ៤៥ ៥៦៧,០លានរៀល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  ២២ ៧៣២,០លានរៀល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  ១០ ១២៣,២លានរៀល
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
  ៣ ៤៦៣,៤លានរៀល

**ចំណាយវិនិយោគបែងចែក**
**៦ ១៥៨ ៨៧២,៩លានរៀល**

- គម្រោងវិនិយោគមិនទាន់បែងចែក
  ៣ ៧៧៣ ៧០០,១លានរៀល
- ថវិកាបដិភាគ
  ៤៤៤ ០៦៧,០លានរៀល
- វិនិយោគដោយមូលនិធិទ្រទ្រង់ថវិកា
  ២៨៣ ៥៥០,៥លានរៀល
- ការទូទាត់ប្រាក់ខ្ចី
  ១ ៦៥៧ ៥៥៥,២លានរៀល

**វិនិយោគសាធារណៈដោយហិរញ្ញប្បទាន**
**ក្រៅប្រទេសអនុវត្តមិនឆ្លងកាត់រតនាគារជាតិ**
**៥ ៨៦៦ ០៦២,០លានរៀល**

# ៥.៣- ហិរញ្ញប្បទាន

- ហិរញ្ញប្បទាន មានគោលបំណងបំពេញឱនភាពសរុបនៃថវិការដ្ឋដែលកើតចេញពីចំណាយថវិការដ្ឋ លើសចំណូលថវិការដ្ឋ។
- សម្រាប់កម្ពុជា ហិរញ្ញប្បទានសម្រាប់ឱនភាពសរុបនៃថវិការដ្ឋ បានមកពី
  - ហិរញ្ញប្បទានពីក្នុងប្រទេស
    - ការបោះផ្សាយមូលបត្ររដ្ឋ
    - បញ្ញើរាជរដ្ឋាភិបាល
  - ហិរញ្ញប្បទានពីក្រៅប្រទេស
    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ
    - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស
- តួលេខហិរញ្ញប្បទានពីក្រៅប្រទេស បានមកពីមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ បូកនឹងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ដកនឹងការទូទាត់ការខ្ចី។



# ៥.៤- ស្ថានភាពបំណុល

## ការខ្ចីក្នុងឆ្នាំ២០២៣




## ស្ថានភាពបំណុល (លានដុល្លារអាមេរិក)




## ការខ្ចីក្រៅប្រទេសក្នុងឆ្នាំ២០២៣




## ទ្វេភាគី




## ពហុភាគី




ប្រភព៖ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា លេខ ២៣ (ខែសីហា ឆ្នាំ២០២៤)

# ៦-ចំណូលនិងចំណាយថវិកាថ្នាក់ក្រោមជាតិ



៦.១- ចំណូលនិងចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត

៦.២-ចំណូលនិងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក

៦.៣-ចំណូលនិងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់





# ៦- ចំណូលនិងចំណាយថវិកាថ្នាក់ក្រោមជាតិ

## ៦.១- ចំណូលនិងចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត

សម្រាប់ថវិកាឆ្នាំ២០២៣ ចំណូលនិងចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលថវិកាសម្រេចបាន៤ ១៨១ ៩២៦,១លានរៀល
- ចំណាយថវិកាសម្រេចបាន៤ ១៧៣ ៣៥៩,២លានរៀល
- អតិរេកថវិការបស់រដ្ឋបាលរាជធានី ខេត្ត ស្មើនឹង៨ ៥៦៦,៩លានរៀល។

ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត




ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត






# ចំណាយរបស់ រដ្ឋបាលរាជធានី ខេត្ត (ឯកតា៖លានរៀល)



រាជធានីភ្នំពេញ៖ ១ ៣៧៩ ៧៨០,៣
- ចំណាយចរន្ត៖ ៩៩២ ៧៩៨,៤
- ចំណាយមូលធន៖ ៣៨៦ ៩៨១,៩

បន្ទាយមានជ័យ៖ ១៨៥ ៦៥០,៤
- ចំណាយចរន្ត៖ ១៧៣ ១៣៦,២
- ចំណាយមូលធន៖ ១២ ៥១៤,២

បាត់ដំបង៖ ១៧៣ ៧១២,១
- ចំណាយចរន្ត៖ ១៦៤ ២៦៥,៧
- ចំណាយមូលធន៖ ៩ ៤៤៦,៤

កំពង់ចាម៖ ១៤១ ២៣៦,៩
- ចំណាយចរន្ត៖ ១៣១ ៩៣៤,៩
- ចំណាយមូលធន៖ ៩ ៣០២,០

កំពង់ឆ្នាំង៖ ៨៥ ៤៥៥,៨
- ចំណាយចរន្ត៖ ៨១ ៩៨៩,៩
- ចំណាយមូលធន៖ ៣ ៤៦៥,៩

កំពង់ស្ពឺ៖ ២១៣ ៥៣៨,១
- ចំណាយចរន្ត៖ ១៣៣ ២១៤,០
- ចំណាយមូលធន៖ ៨០ ៣២៤,១

កំពង់ធំ៖ ៩៧ ៤៧៩,៧
- ចំណាយចរន្ត៖ ៧៥ ១០៤,៥
- ចំណាយមូលធន៖ ២២ ៣៧៥,២

កំពត៖ ១៣៩ ០៦៣,៣
- ចំណាយចរន្ត៖ ១២៤ ០៨១,៤
- ចំណាយមូលធន៖ ១៤ ៩៨១,៩

កណ្តាល៖ ២៩២ ៦៧៧.៩
- ចំណាយចរន្ត៖ ២៦៤ ៧២៣,៩
- ចំណាយមូលធន៖ ២៧ ៩៥៤,០

កោះកុង៖ ៤៣ ៤៦១,៥
- ចំណាយចរន្ត៖ ៣៣ ៤៦៨,៥
- ចំណាយមូលធន៖ ៩ ៩៩៣,០

ក្រចេះ៖ ៥៦ ១៧៣,៧
- ចំណាយចរន្ត៖ ៤២ ៧៩០,៦
- ចំណាយមូលធន៖ ១៣ ៣៨៣,១

មណ្ឌលគិរី៖ ៤៩ ៣៤៨,៦
- ចំណាយចរន្ត៖ ៤៥ ៨៦៦,២
- ចំណាយមូលធន៖ ៣ ៤៨២.៤

ព្រះវិហារ៖ ៤៤ ៥៧៧,០
- ចំណាយចរន្ត៖ ៣៥ ១២៥,៦
- ចំណាយមូលធន៖ ៩ ៤៥១,៤

# ចំណាយរបស់ រដ្ឋបាលរាជធានី ខេត្ត (ឯកតា៖លានរៀល)



**ព្រៃវែង៖ ៩៤ ៧១៣,៦**
- ចំណាយចរន្ត៖ ៨៣ ៧២៥,៦
- ចំណាយមូលធន៖ ១០ ៩៨៨,០

**ពោធិ៍សាត់៖ ១៣១ ៦៩៨,៥**
- ចំណាយចរន្ត៖ ១០០ ៣២២,៥
- ចំណាយមូលធន៖ ៣១ ៣៧៦,០

**រតនគិរី៖ ៤១ ៣៦៨,៦**
- ចំណាយចរន្ត៖ ២៨ ១៥៦,៦
- ចំណាយមូលធន៖ ១៣ ២១២,០

**សៀមរាប៖ ១០៧ ៤៩៦,១**
- ចំណាយចរន្ត៖ ១០៧ ៤៩៦,១
- ចំណាយមូលធន៖ ០

**ព្រះសីហនុ៖ ១១២ ០៣១,៦**
- ចំណាយចរន្ត៖ ៩៥ ៣៤៨,៥
- ចំណាយមូលធន៖ ១៦ ៦៨៣,១

**ស្ទឹងត្រែង៖ ១០៩ ១២៥,៣**
- ចំណាយចរន្ត៖ ៣៩ ៧៥៥,៣
- ចំណាយមូលធន៖ ៦៩ ៣៧០,០

**ស្វាយរៀង៖ ៧៨ ៧៩៨,៨**
- ចំណាយចរន្ត៖ ៧៨ ៤៤៨,៨
- ចំណាយមូលធន៖ ៣៥០,០

**តាកែវ៖ ១៦៧ ១៦៦,២**
- ចំណាយចរន្ត៖ ១៥៨ ១០៨,០
- ចំណាយមូលធន៖ ៩ ០៥៨,២

**ឧត្តរមានជ័យ៖ ៤១ ៣៤៨,០**
- ចំណាយចរន្ត៖ ៣៧ ៣៥៨,០
- ចំណាយមូលធន៖ ៣ ៩៩០,០

**កែប៖ ៣៥ ៩៩១,៦**
- ចំណាយចរន្ត៖ ២០ ០១១,៦
- ចំណាយមូលធន៖ ១៥ ៩៨០,០

**ប៉ៃលិន៖ ១១០ ៤៩៦,៤**
- ចំណាយចរន្ត៖ ១០១ ៩០៩,៣
- ចំណាយមូលធន៖ ៨ ៥៨៧,១

**ត្បូងឃ្មុំ៖ ២៤០ ៩៦៩,៣**
- ចំណាយចរន្ត៖ ១៧៩ ៩៧៧,៣
- ចំណាយមូលធន៖ ៦០ ៩៩២,០

## ៦.២-ចំណូលនិងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក

សម្រាប់ថវិកាឆ្នាំ២០២៣ ចំណូលនិងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រេចបានលទ្ធផលដូចតទៅៈ

- ចំណូលថវិកាសម្រេចបាន៦៥៩ ២៩៤,៨លានរៀល
- ចំណាយថវិកាសម្រេចបាន៦៥០ ១១១,០លានរៀល
- អតិរេកថវិការបស់រដ្ឋបាលក្រុង ស្រុក ស្មើនឹង៩ ១៨៣,៣លានរៀល។

**ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក**




**ចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក**






# ៦.៣-ចំណូលនិងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់

ចំណូលនិងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលថវិកាសម្រេចបាន១ ២៨៧ ២៣៤,៨លានរៀល
- ចំណាយថវិកាសម្រេចបាន១ ១០៧ ៨២៦,៥លានរៀល
- អតិរេកថវិការបស់រដ្ឋបាលឃុំ សង្កាត់ ស្មើនឹង១៧៩ ៤០៨,៣លានរៀល។

**ចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់**




**ចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់**






# ៧-លទ្ធផលទទួលបានពីការអនុវត្តថវិកា សម្រាប់គាំទ្រអាទិភាពគោលនយោបាយ

**ការអនុវត្តថវិកា ឆ្នាំ២០២៣**

១ បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

២ បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យមប្រកបដោយបរិយាបន្ន។

៣ បន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ចត្រឡប់ទៅរកកំណើនសក្តានុពល តាមរយៈការជំរុញការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនិងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣។

៤ ជំរុញការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គមនិងកសាងភាពធន់នៃសង្គមកម្ពុជា សម្រាប់ត្រៀមឆ្លើយតបទៅនឹងគ្រោះអាសន្ន ដែលអាចកើតដោយថាហេតុ។

៥ ដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងប្រាក់ឧបត្ថម្ភមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមក្នុងកម្រិតសមស្រប ដោយផ្អែកលើសមិទ្ធកម្ម ឬ គុណាធិបតេយ្យ ដើម្បីលើកកម្ពស់ជីវភាពរស់នៅព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន និងគុណភាពនៃការផ្តល់សេវាសាធារណៈ។

៦ ដំឡើងប្រាក់សោធន និងកាត់បន្ថយគម្លាតនៃប្រាក់សោធនរវាងអ្នកចូលនិវត្តន៍ចាស់ និងថ្មី ជូនដល់អតីតមន្ត្រីរាជការស៊ីវិល និងអតីតកងកម្លាំងប្រដាប់អាវុធ។

៧ បន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

៨ ជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតង សំដៅលើកកម្ពស់ការតភ្ជាប់ក្នុងសេដ្ឋកិច្ច គាំទ្រការធ្វើបរិវត្តកម្មឌីជីថល និងអភិវឌ្ឍប្រកបដោយចីរភាព។

៩ បន្តគាំទ្រការអភិវឌ្ឍនៃសហគ្រាសធុនតូចនិងមធ្យម តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ច។

១០ ជានាជោគជ័យនៃកិច្ចដំណើរការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៧ និងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ ព្រមទាំងការត្រៀមសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភានីតិកាលទី៥។

# ៨-សេចក្ដីសន្និដ្ឋាន




ជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង ទាំងក្នុងនិងក្រៅប្រទេស សំដៅបន្តការពារអាយុជីវិត លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋព្រមទាំងស្ដារនិងជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ចកម្ពុជា តាមគន្លងប្រក្រតភាពថ្មី។

អាចប្រសិទ្ធនាមបានថាជា ថវិកាវិត្តារកម្មចំគោលដៅ ដោយផ្ដល់អាទិភាពទី១ ដល់មនុស្សពិសេសលើសុខភាព ជីវភាព និងសមធម៌ ព្រមជាមួយនឹងអាទិភាពនៃការបន្តជំរុញការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣។

ត្រូវបានប្រើប្រាស់ដើម្បីសម្រេចឱ្យបានជាអតិបរមានូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ស្របតាមរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣។

រៀបចំដោយ
នាយកដ្ឋានគោលការណ៍គណនេយ្យនិងវិភាគការអនុវត្តថវិកា
អគ្គនាយកដ្ឋានរតនាគារជាតិ

សូមស្កេនកូដខាងក្រោម
ដើម្បីទាញយកឯកសារ

ច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣